ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**

លេខ: ១៦៤ ស.ស.រ./គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៣

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារផ្តល់យោបល់សម្រាប់អនុវត្តគម្រោងលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

## លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស /រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស /រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត/១២០៨/១៤២៩ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

- បានឃើញអនុក្រឹត្យលេខ ២៣៤ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ២០១១ ស្តីពីការកែសម្រួលមាត្រា ៤ មាត្រា ៧ មាត្រា ១២ មានត្រា ១៣  មាត្រា១៥ មាត្រា១៦ និងមាត្រា ១៧ នៃអនុក្រឹត្យលេខ ២៣ អនក្រ .បក ស្តីបីការរៀបចំ និង ប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន គ.ជ.អ.ប
- យោងតាមការសំណើរបស់គម្រោងលើកកំពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតយ្យនៅថ្នាក់ក្រោមជាតិ

## សម្រេច

**ប្រការ ១.**

បង្កើតក្រុមការងារផ្តល់យោបល់សម្រាប់អនុវត្តគម្រោងលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរ-ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (PROCEED) ។

**ប្រការ ២.**

ក្រុមការងារផ្តល់យោបល់សម្រាប់អនុវត្តគម្រោងលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ មានសមាសភាពដូចខាងក្រោម:

| | | |
|---|---|---|
| ១- ឯកឧត្តម **ចាន់ ចំរើន** | អនុប្រធានប្រតិបត្តិនៃលេខាធិការដ្ឋាន គ.ជ.អ.ប | សហប្រធាន |
| ២- លោកស្រី **សារ៉ា ស៊ីតស៍** | តំណាងប្រចាំប្រទេសនៃអង្គការផេក | សហប្រធាន |
| ៣- ឯកឧត្តម **ជាម យៀរ** | ប្រធានអង្គភាពត្រួតពិនិត្យ វាយតម្លៃ និងពត៌មាន នៃលេខាធិការដ្ឋាន គ.ជ.អ.ប | អនុប្រធាន |
| ៤-ឯកឧត្តម **សយ កុសល** | តំណាងសម្ព័ន្ធភាពឃុំ សង្កាត់ | សមាជិក |
| ៥-លោក **ហួត ស៊ីនាដ** | អនុប្រធានអង្គភាពវិភាគ និងអភិវឌ្ឍគោលនយោបាយ នៃលេខាធិការដ្ឋាន គ.ជ.អ.ប | សមាជិក |
| ៦-លោក **ម៉ែន សៅរី** | អនុប្រធានក្រុមការងារសម្របសម្រួលការបង្កើតសមាគម ថ្នាក់ក្រោមជាតិ | សមាជិក |
| ៧-លោក **ជា ចាន់ថា** | តំណាងក្រុមការងារវិមជ្ឈការតាមរយៈភាពដៃគូរ | សមាជិក |
| ៨-លោកស្រី **ចេត ចរិយា** | តំណាងក្រុមការងារវិមជ្ឈការតាមរយៈភាពដៃគូរ | សមាជិក |
| ៩- លោកស្រី **ហុង សុខណ្ណារី** | អ្នកសម្របសម្រួលផ្នែកបណ្តុះបណ្តាលនៃអង្គការសីលការ | សមាជិក |
| ១០- លោកស្រី **អ៊ឹម យក់ឃន** | នាយិកានៃអង្គការអមរា | សមាជិក |

| | | |
|---|---|---|
| ១១- លោក **សៀ៊ង សារឿន** | នាយកប្រតិបត្តិអង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា | សមាជិក |
| ១២- លោក **ហេង សុខ** | អ្នកជំនាញផ្នែកគ្រប់គ្រងគ្រោះមហន្តរាយ និងអភិបាលកិច្ចនៃអង្គការវ៉ែលនអន្តរជាតិ | សមាជិក |
| ១៣-លោក **ឈយ ចន្ទសុផល** | នាយកកម្មវិធីវិមជ្ឈការ និងអភិបាលកិច្ចនៃអង្គការផេក | សមាជិកអចិន្ត្រៃយ៍ |

**ប្រការ ៣.**

ក្រុមការងារផ្តល់យោបល់ មានតួនាទី ភារកិច្ច ដូចខាងក្រោម៖

- ផ្តល់យោបល់ផ្នែកច្បាប់ និងគោលនយោបាយនានា ដល់ការអនុវត្តគម្រោង
- ផ្តល់ការគាំទ្រដល់អនុវត្តគម្រោងលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដោយបញ្ចូល
  ១. យន្តការការចូលរួមរបស់ប្រជាពលរដ្ឋទៅក្នុង ដំណើរការអភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ
  ២. យន្តការផ្សព្វផ្សាយពតិមានរបស់ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក
  ៣. យន្តការតវ៉ានៅថ្នាក់ក្រោមជាតិ
- ផ្តល់អនុសាសន៍នានាដើម្បីធ្វើឱ្យស៊ីសង្វាក់ជាមួយនឹងក្របខណ្ឌគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- ផ្តល់អនុសាសន៍នានាដើម្បីសម្រេចឱ្យបាននូវគោលដៅរបស់គម្រោង
- លើកកំពស់ទំនាក់ទំនង កិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលនានារវាងគម្រោង ជាមួយក្រសួង-ស្ថាប័ននៅថ្នាក់ជាតិ និងជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ និងស្ថាប័នពាក់ព័ន្ធដ៏ទៃទៀត
- ចែករំលែកបទពិសោធន៍នៃការអនុវត្តគម្រោងទៅឱ្យក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូរអភិវឌ្ឍ និងអង្គការសង្គមស៊ីវិល។

**ប្រការ ៤.**

ក្រុមការងារផ្តល់យោបល់សម្រាប់អនុវត្តគម្រោងលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវរៀបចំកិច្ចប្រជុំសមញ្ញ ឱ្យបានយ៉ាងតិចចំនួន ២ ដង នៅក្នុងរយៈពេល ១ ឆ្នាំ ដើម្បីពិនិត្យអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនានា ផ្តល់យោបល់ និងអនុសាសន៍ក្នុងការអនុវត្តគម្រោង។ ក្នុងករណីចាំបាច់ និងបន្ទាន់ ក្រុមការងារអាចរៀបចំកិច្ចប្រជុំវិសាមញ្ញបាន តាមការស្នើសុំពីប្រធានក្រុម-

ការងារផ្ដល់យោបល់។ កិច្ចប្រជុំរបស់ក្រុមការងារ ត្រូវប្រព្រឹត្តទៅនៅលេខាធិការដ្ឋាន គ.ជ.អ.ប ឬទីកន្លែងដ៏ទៃទៀត តាមការកំណត់របស់ប្រធានក្រុមការងារផ្ដល់យោបល់ និងពីគម្រោង។

**ប្រការ ៥.**

លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវផ្ដល់ការគាំទ្រ និងកិច្ចសហការនានា ដើម្បីឱ្យការអនុវត្តគម្រោងលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ទទួលបានជោគជ័យ សម្រេចបាននូវគោលដៅគម្រោង និងត្រូវជួយសម្រួលដល់ការរៀបចំកិច្ចប្រជុំនានារបស់ក្រុមការងារផ្ដល់យោបល់។

**ប្រការ ៦.**

សេចក្ដីសម្រេចនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**រដ្ឋលេខាធិការ**

**និងជាប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**

សក់_សេដ្ឋា